# ម្តាយខ្ញុំ

*បទពាក្យ៧*

ម្តាយ ខ្ញុំ គិតទៅជាព្រះរស់
ម្តាយ ខ្ញុំ រងព្រួយមិនចេះបាត់
ម្តាយ ខ្ញុំ ធ្វើការមិនខ្លាចហត់
ម្តាយ ខ្ញុំ បួងជាឲ្យកូនសួន
ម្តាយ ខ្ញុំ ក្រោមថ្ងៃលោកមិនក្តៅ
ម្តាយ ខ្ញុំ ទោះគ្រុនមិនរាងចាល
ម្តាយ ខ្ញុំ ទោះការច្រើនយ៉ាងណា
ម្តាយ ខ្ញុំ ខោអាវស្លៀកតោកយ៉ាក
ម្តាយ ខ្ញុំ វាយកូនស្រែកក្តែងៗ
ម្តាយ ខ្ញុំ ពិសាបបរស
ម្តាយ ខ្ញុំ មានក្លិនមិនល្អល្អះ
ម្តាយ ខ្ញុំ ជំពាក់គេគ្រប់តួប
ម្តាយ ខ្ញុំ ម្នាក់ឯងមិនពីសារ
ម្តាយ ខ្ញុំ ភថាឆ្អែតឥតបី
ម្តាយ ខ្ញុំលុយចាយគាត់មិនមាន
ម្តាយ ខ្ញុំ មានលុយទុកសាងក្បូន
ម្តាយ ខ្ញុំ មានគុណពន់មិនអស់
ម្តាយ ខ្ញុំ ព្រះពិតឥតងាករេ

ម្តាយ ខ្ញុំ មានឈ្មោះពោធិសត្វ
ម្តាយ ខ្ញុំ ចែងចាត់មិនដេកពួន។
ម្តាយ ខ្ញុំ ស៊ូអត់ចិត្តមាំមួន
ម្តាយ ខ្ញុំ គ្រាំខ្លួនមិនវាចា។
ម្តាយ ខ្ញុំ កូនខ្លៅគាត់ខ្លោចផ្សា
ម្តាយ ខ្ញុំ ធ្វើការមិនសំរាក។
ម្តាយ ខ្ញុំ មិនថាការលំបាក
ម្តាយ ខ្ញុំ រខាកឲ្យកូនល្អ។
ម្តាយ ខ្ញុំ ខ្លួនឯងអួលដើមក
ម្តាយ ខ្ញុំ ត្រេកអរកូនបាយស្រួប។
ម្តាយ ខ្ញុំ សុខណាស់កូនក្រអូប
ម្តាយ ខ្ញុំ ជឿម្ជូបឲ្យកូនឆី។
ម្តាយ ខ្ញុំ លាក់ការនំចំណី
ម្តាយ ខ្ញុំ លបឆីសល់ពីកូន។
ម្តាយ ខ្ញុំ លុយរៀនប្រាក់កេរដូន
ម្តាយ ខ្ញុំក្បត់កូនគាត់គ្មានទេ។
ម្តាយ ខ្ញុំ ចិត្តស្មោះល្អលើសគេ
ម្តាយ ខ្ញុំ ល្អទ្វេរាល់ៗថ្ងៃ។

សូយ ឡុត

*ស្រីសន្ធរ ថ្ងៃទី០៣ កុម្ភៈ ២០០៣*